**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ៥០៤ សស.ម.ល.

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលលក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័ក នៅកម្ពុជាសម្រាប់អ្នកដំណើរចូលកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បានឃើញអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ .–**

ត្រូវបានកែសម្រួលលក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័កនៅកម្ពុជាសម្រាប់អ្នកដំណើរចូលកម្ពុជាស្របតាមគន្លងប្រក្រតីភាពថ្មីដូចខាងក្រោម÷

១-អ្នកដំណើរដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ ត្រូវភ្ជាប់មកជាមួយនូវបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ និងវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ (តេស្ត PCR) ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី ឬប្រទេសសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា។ ពេលមកដល់កម្ពុជា ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Rapid Test) នៅច្រកចូលប្រទេស ហើយត្រូវរង់ចាំលទ្ធផលតេស្តនេះ។ បន្ទាប់ពីទទួលបានលទ្ធផលតេស្តកូវីដ-១៩ អវិជ្ជមាន បុគ្គលមិនតម្រូវឱ្យធ្វើចត្តាឡីស័កឡើយ និងអាចធ្វើដំណើរដោយសេរីទូទាំងប្រទេសកម្ពុជា។ ក្នុងករណីទទួលបានលទ្ធផលតេស្តកូវីដ-១៩ វិជ្ជមាន អ្នកជំងឺអាចដាក់ឱ្យព្យាបាលឬបញ្ជូនទៅកន្លែងព្យាបាលដែលអនុញ្ញាតដោយក្រសួងសុខាភិបាល។

២-ចំពោះអ្នកដំណើរដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ ហើយធ្វើដំណើរចូលមកកម្ពុជា តម្រូវឱ្យយកសំណាកធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Rapid Test) នៅច្រកចូលប្រទេស ហើយត្រូវរង់ចាំលទ្ធផលតេស្តនេះ។ បន្ទាប់ពីទទួលបានលទ្ធផលតេស្តកូវីដ-១៩ អវិជ្ជមាន បុគ្គលតម្រូវឱ្យធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច និងធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី១៣ នៃការធ្វើចត្តាឡីស័ក។ ប្រសិនបើទទួលបានលទ្ធផលតេស្តកូវីដ-១៩ វិជ្ជមាន អ្នកជំងឺអាចដាក់ឱ្យព្យាបាលឬបញ្ជូនទៅកន្លែងព្យាបាលដែលអនុញ្ញាតដោយក្រសួងសុខាភិបាល។ អ្នកដំណើរត្រូវមានឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក។ ក្នុងករណីពុំមានការកក់សណ្ឋាគារ ត្រូវត្រៀមសាច់ប្រាក់ចំនួន ២,០០០ ដុល្លារអាម៉េរិក (សម្រាប់អ្នកដំណើរបរទេស) ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។

៣-ក្នុងករណីត្រូវការទិដ្ឋាការដើម្បីធ្វើដំណើរមកកម្ពុជា អ្នកដំណើរត្រូវស្នើសុំទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា មិនទាន់អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ។

៤-ការទទួលខុសត្រូវក្នុងការព្យាបាលជំងឺកូវីដ-១៩ សម្រាប់អ្នកដំណើរជាជនបរទេស÷

៤.១.- សម្រាប់អ្នកដំណើរជាជនបរទេស (លើកលែងមន្ត្រីការទូត និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ ដែលកាន់ទិដ្ឋាការការទូត (Visa A) និងទិដ្ឋាការផ្លូវការ (Visa B) និងក្រុមគ្រួសារ) ត្រូវទទួលខុសត្រូវខ្លួនឯងក្នុងការព្យាបាល ក្នុងករណីឆ្លងជំងឺកូវីដ-១៩ ឬមានជំងឺផ្សេងទៀត។

៤.២.- អ្នកដំណើរជាជនបរទេស ត្រូវបានលើកទឹកចិត្តឱ្យទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (COVID-19 Health Insurance Policy) ដែលនៅកម្ពុជាអាចទិញពីការធានារ៉ាប់រងរួមគ្នា (Insurance consortium) តំណាងដោយក្រុមហ៊ុនធានារ៉ាប់រងហ្វតេ តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/។

៥-អ្នកដំណើរដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ ហើយកំពុងធ្វើចត្តាឡីស័ក នៅតាមមណ្ឌលចត្តាឡីស័ក សណ្ឋាគារ ឬគេហដ្ឋាននៅទូទាំងប្រទេស ត្រូវអនុញ្ញាតឱ្យបញ្ចប់ការធ្វើចត្តាឡីស័ក ប្រសិនបើទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Rapid Test) អវិជ្ជមាន។

**ប្រការ២ .–**

សេចក្តីសម្រេចលេខ៤៥៦ សខល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .–**

ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ អនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសុខាភិបាល ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈប្រចាំការនៃ **គ.ប.គ.**
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ